**ប្រភពជំនួយក្នុងតំបន់**

**Greenfield** (គ្រីនហ្វៀល)

NELCWIT 413-772-0806 **ទូរស័ព្ទបន្ទាន់** មិនគិតប្រាក់ 1-888-249-0806 24 ម៉ោង/7 ថ្ងៃ

SAFEPLAN អ្នកជួយគាំទ្រនៅតុលាការ 413-772-0806

សហគមន៍ជំនួយផ្លូវច្បាប់ (Community Legal Aid) 413-774-3747

មជ្ឈមណ្ឌលសំរាប់អាមេរិកាំងថ្មី (Center for New Americans) 413-772-0055

**Orange** (អ័រេញ)

NELCWIT 978-544-9857 **ទូរស័ព្ទបន្ទាន់** មិនគិតប្រាក់ 1-888-249-0806 24 ម៉ោង/7 ថ្ងៃ

SAFEPLAN អ្នកជួយគាំទ្រនៅតុលាការ 978-544-9857

**Northampton** (នសហេមតុន)

Safe Passage 413-586-5066 **ទូរស័ព្ទបន្ទាន់** មិនគិតប្រាក់ 1-888-345-5282 24 ម៉ោង/7 ថ្ងៃ

SAFEPLAN អ្នកជួយគាំទ្រនៅតុលាការ 413-586-4545

សហគមន៍ជំនួយផ្លូវច្បាប់ (Community Legal Aid) 413-584-4034

មជ្ឈមណ្ឌលសំរាប់អាមេរិកាំងថ្មី (Center for New Americans) 413-587-0084

**Amherst/Belchertown** (អេមហឺស/ បែលជឺថោន )

មជ្ឈមណ្ឌលសំរាប់ស្ត្រីនិងសហគមន៍ (Center for Women and Community) 413-545-0800

**ទូរស័ព្ទបន្ទាន់** មិនគិតប្រាក់ 1-888-337-0800 24 ម៉ោង/7 ថ្ងៃ

SAFEPLAN អ្នកជួយគាំទ្រនៅតុលាការ 413-323-1197

មជ្ឈមណ្ឌលសំរាប់អាមេរិកាំងថ្មី (Center for New Americans) 413-259-3288

**Statewide** (ទូទាំងរដ្ឋ)

បណ្តាញការងារថ្នាក់ជាតិសំរាប់សិទ្ធិជនអន្តោប្រវេសន្ត និងជនភៀសខ្លួន (National Network for Immigrant and Refugee Rights) 510-465-1984

កម្មវិធីយុត្តិធ៌មរដ្ឋម៉ាស្សាជូសេត្ស៍ (Massachusetts Justice Project) 1-800-639-1209

កម្មវិធីអំពើហិង្សាប្រឆាំងប្រុសស្រឡាញ់ភេទដូចគ្នា (Gay Men's Domestic Violence Project) 1-800-832-1901 **ទូរស័ព្ទបន្ទាន់** មិនគិតប្រាក 24 ម៉ោង/7 ថ្ងៃ

"គ្រោងការណ៍នេះបានមកពីការគាំទ្រប្រាក់ជំនួយបន្តលេខ ឧបត្ថម្ភដោយការិយាល័យដឹកនាំរបស់រដ្ឋសំរាប់កម្មវិធីថវិកា STOP Formula។ មតិ, ការសម្រេច, ការសន្និដ្ឋាន និងអនុសាសន៍បញ្ចេញក្នុងការបោះពុម្ភ/កម្មវិធី/ពិព៌ណនេះ គឺជារបស់អ្នកនិពន្ធ ហើយមិនមែនជាទស្សនៈរបស់រដ្ឋ ឬក៏ក្រសួងយុត្តិធ៌មជាតិ, ការិយាល័យផ្នែកអំពើហិង្សាប្រឆាំងនឹងស្ត្រីឡើយ។

December, 2012

# តើអ្នកខ្លាចប្តី ឬដៃគូសិនិទ្ធរបស់អ្នកឬទេ?

# តើអ្នកជាពលរដ្ឋអាមេរិកាំងមិនទាន់ចូលសញ្ជាតិឬ?




# តើអ្នកខ្លាចមិនហ៊ានទៅរកប៉ូលីសឲ្យជួយ មែនទេ?

# យើងចង់ជួយ!

**គ្រោងការណ៍របស់មេធាវីតំបន់ពាយព្យ**

**(Project of Northwestern District Attorney)**

**David E. Sullivan**

NorthwesternDA.org

ប្ដី
សង្សារប្រុស
ប្រពន្ធ
សង្សារស្រី

**តើដៃគូសិនិទ្ធរបស់អ្នក ..........**

- ចង់ដឹងថា តើអ្នកនៅឯណាគ្រប់ពេលវេលាទាំងអស់?
- ប្រាប់អ្នក ពីសម្លៀកបំពាក់ណាដែលអ្នកត្រូវស្លៀក?
- រារាំងអ្នកមិនឲ្យជួបមិត្តភក្តិ ឬគ្រួសារ?
- បន្ទោស ថាអ្នកជាមនុស្សភ្លើ, ខ្ជិលច្រអូស ឬអាក្រក់?
- ធ្វើឲ្យឈឺដល់សរីរាង្គកាយរបស់អ្នក?
- និយាយថា គាត់នឹងយកកូនទៅឲ្យឆ្ងាយពីអ្នក?
- គំរាមកំហែងថានឹងសម្លាប់អ្នក?

**តើដៃគូសិនិទ្ធរបស់អ្នកប្រើរឿងអន្តោប្រវេសន៏របស់អ្នកប្រឆាំងនឹងអ្នកដោយ......**

- និយាយថា ប៉ូលីសនឹងចាប់**អ្នក**?
- ធ្វើការគំរាមថា នឹងឲ្យគេបញ្ជូនអ្នកទៅស្រុកវិញ?
- បំផ្លាញលិខិតឆ្លងដែន, ប័ណ្ណសំគាល់ខ្លួន, ប័ណ្ណសុខភាព ឬក្រដាសស្នាមសំខាន់ៗ ដទៃទៀតរបស់អ្នក?

**តើដៃគូសិនិទ្ធរបស់អ្នកប្រើឧបសគ្គខាងវប្បធម៌ ឬភាសាធ្វើឲ្យអ្នកវង្វេង ឬយល់ខុសដោយ.........**

- និយាយថា គេអាចដកហូតសញ្ជាតិ ឬក៏ភាពជាអន្តោប្រវេសន៍ពីអ្នក?
- កុហកពីច្បាប់របស់សហរដ្ឋអាមេរិក?

បើអ្នកបានឆ្លើយថា **បាទ/ចា៎** ទៅនឹងសំណួរណាមួយខាងលើ
អ្នកប្រហែលជាស្ថិតនៅក្នុងសម្ពន្ធភាពដែលមានអំពើធ្វើបាប
**ហើយវាមិនមែនជាកំហុសរបស់អ្នកទេ!**

**នៅក្នុងសហរដ្ឋអាមេរិក វាជាការល្មើសច្បាប់សំរាប់បុគ្គលណាម្នាក់ ប្រើកម្លាំងបាយធ្វើបាបដៃគូរសិនិទ្ធរបស់ខ្លួន!!!**



## បើអ្នកជាជនអន្តោប្រវេសន្ត និងជាជនរងគ្រោះនៃអំពើឧក្រិដ្ឋ
## អ្នកអាចដាក់ពាក្យសុំយូ -វីស្សា (U-VISA)បាន!!!

### តើយូ -វិស្សាជាអ្វី?

វាជាឯកសារមួយរបស់រដ្ឋាភិបាលអាមេរិកដែលផ្ដល់សិទ្ធិដល់ជនអន្តោប្រវេសន្តឲ្យស្នាក់នៅក្នុងប្រទេសអាមេរិក។ បើត្រូវបានគេយល់ព្រមហើយ អ្នកនិងកូនៗរបស់អ្នកអាចស្នាក់នៅក្នុងសហរដ្ឋអាមេរិកដើម្បីធ្វើការដល់ទៅ ៤ឆ្នាំ។ បន្ទាប់ពី ៣ឆ្នាំក្រោយពីការដាក់ពាក្យសុំដំបូងបំផុត អ្នកអាចដាក់ពាក្យសុំធ្វើជាពលរដ្ឋពេញច្បាប់របស់សហរដ្ឋអាមេរិក(គ្រីនខាត)។

### តើខ្ញុំទទួលបានដោយរបៀបណា?

ដើម្បីទទួលបានយូ-វិស្សា អ្នកត្រូវតែប្រាប់ប៉ូលីសពីអំពើឧក្រិដ្ឋ និងមានបំណងដើម្បីសហការ ក្នុងសំណុំរឿង។ បន្ទាប់មក អ្នកត្រូវតែយកសំបុត្របញ្ជាក់ពីមន្ត្រីសមត្ថកិច្ចសហរដ្ឋ, រដ្ឋ, ឬក៏ក្រុង ដូចជាពីប៉ូលីស ឬក៏ការិយាល័យរដ្ឋអាជ្ញាប្រចាំតំបន់។

**រដ្ឋាភិបាលសហរដ្ឋនឹងសម្រេច ថាតើអ្នកត្រូវគេយល់ព្រមចេញយូ -វីស្សាឲ្យ ឬអត់។**




ការការពារក៏អាចមានជូនបានក្រោមច្បាប់ការពារ
អំពើហិង្សាប្រឆាំងស្ត្រីភេទ **(VAWA)**
**(Violence Against Women Act)**
ចូរទាក់ទងសហគមន៍ជំនួយផ្នែកផ្លូវច្បាប់សំរាប់ព៌តមានបន្ថែម



## តើខ្ញុំគួរតែនៅ ឬ គួរតែទៅ?

មិនថាឡើយ អ្នកសម្រេចថាចាកចេញ ឬក៏អត់, វាជាការល្អក្នុងការគ្រោងទុកជាមុន សំរាប់ករណីដែលអ្នកត្រូវការគេចចេញជាបន្ទាន់។

ត្រូវត្រៀមខ្លួនដោយលាក់របស់ទាំងនេះនៅកន្លែងនិរភ័យ:

- ឯកសារសំខាន់ៗ: លិខិតឆ្លងដែន, ឯកសារចូលសញ្ជាតិ, ប័ណ្ណសំគាល់ខ្លួន, ប័ណ្ណសុខភាព, ឬឯកសារពេទ្យ និងឯកសារទាក់ទងប្រាក់កាក់
- កូនសោបំរុង
- សម្លៀកបំពាក់ពីរកំប្លេសំរាប់អ្នកនិងកូនៗ
- បញ្ជីលេខទូរស័ព្ទភាពអាសន្ន និងទូរស័ព្ទបំរុងដែលមានថ្មគ្រប់គ្រាន់
- ប្រាក់កាក់ដែលបានបំរុងទុកជាមុន

អនុវត្តនូវវិធីចាកចេញដោយសុវត្ថិភាព និងជួយនាំកូនៗ អនុវត្តផង។

ទាក់ទងទៅបណ្តាញបន្ទាន់នៅខាងខ្នងនៃកូនសៀវភៅតូចនេះដើម្បីពិភាក្សាជាមួយអ្នកដែលអាចជួយអ្នកត្រៀមគ្រោងការណ៍សុវត្ថិភាព។



## មានកន្លែងច្រើនដែលអ្នកអាចទៅរកគេជួយ ដោយមិនបាច់បារម្ភពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកឡើយ!

| កន្លែងអ្វីខ្លះ? | ជួយអ្វីខ្លះ? |
|---|---|
| ~ **NELCWIT** Greenfield<br>~ **Safe Passage** Northampton<br>~ **Center for Women and Community** Amherst | គ្រាន់តែនិយាយជាមួយអ្នកណាម្នាក់ដែលនឹងស្តាប់ ហើយនិងជួយអ្នកត្រៀមខ្លួននិងគ្រួសារដើម្បីការពារអ្នក និងគ្រួសារអ្នកឲ្យមានសុវត្ថិភាព |
| ~ **Community Legal Aid** (សហគមន៍ជំនួយផ្នែកច្បាប់) Northampton | ជួយខាងស្ថានភាពអន្តោប្រវេសន៍ឲ្យបានស្របច្បាប់ |
| ~ **តុលាការនៅ** Greenfield, Northampton, Orange, និង Belchertown | អ្នកជួយគាំទ្រនៅក្នុងតុលាការនឹងពន្យល់ពីការជ្រើសរើសផ្សេងៗ ដើម្បីឲ្យអ្នកបានទទួលបញ្ជាទប់ស្កាត់ប្រឆាំងនឹងបុគ្គលដែលបំពានធ្វើបាបអ្នក |

~ *លេខទូរស័ព្ទរបស់អង្គការទាំងនោះត្រូវគេសរសេរខាងខ្នងនៃកូនសៀវភៅតូចនេះ។*

**អ្នកមិនចាំបាច់ប្រាប់អ្នកដទៃពីតមានរស់នេះទេ បើសិនជាអ្នកមិនចង់ឲ្យគេដឹង។**

**អ្នកមិចចាំបាច់ប្រាប់ពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកទេ បើសិនជាអ្នកមិនចង់និយាយ។**

## អ្នកអាចដាក់ពាក្យសុំបញ្ជាទប់ស្កាត់ នៅឯតុលាការក្នុងតំបន់ដែលអ្នករស់នៅ



## *តើមានអ្វីកើតឡើងនៅពេលដែលខ្ញុំទៅតុលាការ?*

- សន្តិសុខតុលាការនឹងសុំឲ្យអ្នកទាំងអស់គ្នាដើរឆ្លងទ្វារពិនិត្យជាតិដែក និងសុំឆែកមើលថង់ ឬកាបូប
- អ្នកអាច**សុំឲ្យមានអ្នកជួយគាំទ្រម្នាក់**ជួយអ្នកឆ្លងកាត់ដំណើរការនៅក្នុងការិយាល័យក្រឡាបញ្ជី ដែលមាននៅក្នុងគ្រប់តុលាការទាំងអស់។
- អ្នកមានសិទ្ធិដាក់ពាក្យសុំ**បញ្ជាទប់ស្កាត់** ដែលជាឯកសារតុលាការដែលអាចបញ្ជាឲ្យបុគ្គលដែលធ្វើបាបអ្នកនោះចុះចេញពីផ្ទះ ហើយនៅឲ្យឆ្ងាយពីអ្នកនិងកូនរបស់អ្នក។
- បើអ្នកសម្រេចថាដាក់ពាក្យសុំបញ្ជាទប់ស្កាត់ អ្នកជួយគាំទ្រនឹងសួរសំណួរផ្ទាល់ខ្លួនអំពីទំនាក់ទំនងរបស់អ្នក និងហេតុអ្វីបានជាអ្នកខ្លាច។ គេនឹងសុំឲ្យអ្នកសរសេរអ្វីៗ ដែលកើតឡើងទាំងប៉ុន្មានជាភាសារបស់អ្នក។ បើសិនជាអ្នកមិនចេះសរសេរ គេនឹងមានអ្នកបកប្រែម្នាក់ឲ្យជួយអ្នក។ វាអាចមានការលំបាកក្នុងការនិយាយប្រាប់រឿងផ្ទាល់ខ្លួន ប៉ុន្តែវានឹងជួយឲ្យអ្នកបានទទួលការការពារដែលអ្នកត្រូវការ។
- **ចៅក្រមនឹងសម្រេច** ថាតើចេញបញ្ជាទប់ស្កាត់នោះឲ្យ ឬអត់។

**អ្នកមានសិទ្ធិសុំការជួយពីអ្នកបកប្រែដែលមានក្របខ័ណ្ឌគ្រប់គ្រាន់ ដែលនិយាយភាសារបស់អ្នក។**

## តើមានការការពារបែបណាខ្លះដែល បញ្ជាទប់ស្កាត់នោះអាចជួយបាន?

**អ្នកអាចសុំឲ្យគេដាក់នៅក្នុងបញ្ជានោះនូវចំណុចខ្លះៗ ឬចំណុចទាំងអស់ដូចតទៅ:**

*បញ្ជាឲ្យអ្នកដែលបំពានធ្វើបាបនោះ:*

- ឈប់ធ្វើបាបអ្នក
- ហាមគេទាក់ទងជាមួយអ្នក។ អ្នកនោះមិនអាចទាក់ទងអ្នក ឬកូនៗរបស់អ្នកបានរយៈតាមទូរស័ព្ទ សារតាមទូរស័ព្ទ អ៊ីមែល ឬក៏សំបុត្រឡើយ។
- ចុះចេញ ហើយនិងនៅឲ្យឆ្ងាយពីគេហដ្ឋាន និងកន្លែងធ្វើការរបស់អ្នក។
- គោរពតាមបញ្ជាអាណាព្យាបាលណ្តោះអាសន្នសំរាប់កូនៗ របស់អ្នក
- បង់ប្រាក់គាំទ្របណ្តោះអាសន្ន
- ប្រគល់សោផ្ទះដល់អ្នក
- ឲ្យមានវត្តមានប៉ូលីសនៅពេលគេទៅយករបស់របរកម្មសិទ្ធិគេ
- ប្រគល់អាវុធទាំងអស់




**អ្នកអាចទៅរកបញ្ជាទប់ស្កាត់បាន នោះបីអ្នកមិនមែនជាសញ្ជាតិអាមេរិកាំងក៏ដោយ។**